**ឯកសារសង្ខេប**

ក្រុមសមាជិកា ព្រឹទ្ធសភា

# "ប្រសិទ្ធភាព ការដឹកនាំ និងការគ្រប់គ្រង តាមសមធម៌យេនឌ័រ"

អ្នកស្រាវជ្រាវ៖ **ជា ម៉ាលីកា**

ខែមេសា ឆ្នាំ២០១៤

**វិទ្យាស្ថានសភាកម្ពុជា**

# មាតិកា


សេចក្តីផ្តើម........................................................................................................ 1

I. ស្ថានភាពបច្ចុប្បន្នរបស់សមាជិកាក្រុមប្រឹក្សានៅក្នុងប្រទេសកម្ពុជា ................................... 1

I.1 ចំនួនក្រុមប្រឹក្សាជាស្ត្រីធៀបទៅនឹងបុរសនៅក្នុងប្រទេសកម្ពុជា និងធៀបទៅនឹងប្រទេសនៅក្នុងតំបន់ ................................................................................................ 2

I.2. ការដឹកនាំ និង គ្រប់គ្រងរបស់សមាជិកាក្រុមប្រឹក្សា ........................................................ 5

II. គោលនយោបាយដែលមានស្រាប់.................................................................................. 6

III. បញ្ហាគន្លឹះ និងការប្រឈមសំខាន់ៗ.............................................................................. 7

IV. បទពិសោធន៍ពីអន្តរជាតិ ........................................................................................... 9

សេចក្តីសន្និដ្ឋាន ........................................................................................................ 10

**សេចក្តីផ្តើម**

ការបោះឆ្នោតឃុំ/សង្កាត់ដែលបានចាប់ផ្តើមតាំងពីឆ្នាំ២០០២ គឺជាដំនាក់កាលសំខាន់បំផុតក្នុងដំណើរការឆ្ពោះទៅកាន់វិមជ្ឈការបែបប្រជាធិបតេយ្យនៅកម្ពុជា ។ ការរៀបចំកំណែទម្រង់សារជាថ្មីនេះមិនត្រឹមតែបង្កើតឳកាសសម្រាប់តំណាងនយោបាយបន្ថែមប៉ុណ្ណោះទេ គឺថែមទាំងដោះស្រាយបញ្ហាសមភាពយេនឌ័រនៅក្នុងនយោបាយថ្នាក់មូលដ្ឋានថែមទៀតផង ។ ទោះជាយ៉ាងណាក៏ដោយ ក៏កំណែទម្រង់ទាំងនេះនៅតែជួបនឹងបញ្ហាប្រឈមសំខាន់ៗ ជាពិសេសនៅក្នុងបញ្ហាយេនឌ័រ និងបង្កើតរចនាសម្ព័ន្ធដែលផ្តល់អំណាចដល់ស្រ្តី[1] ។

*សារៈសំខាន់នៃការចូលរួមរបស់ស្រ្តីនៅក្នុងនយោបាយ[2]:*

- បង្ហាញថាស្រ្តីអាចចូលរួមក្នុងការងារនយោបាយបានដោយប្រសិទ្ធភាព
- នយោបាយគ្របដណ្តប់លើវិស័យ និងបញ្ហាដែលស្រ្តីជួបប្រទះជាប្រចាំថ្ងៃ
- ធ្វើអោយស្រ្តីអាចចូលរួមក្នុងការសម្រេចចិត្ត និងក្នុងតួនាទីជាអ្នកដឹកនាំ
- ការចូលរួមរបស់ស្រ្តីក្នុងវិស័យនយោបាយនឹងធ្វើអោយមានការផ្លាស់ប្តូរជាវិជ្ជមានដល់សង្គមទាំងមូល

មានស្រ្តីជាតំណាងនៅថ្នាក់មូលដ្ឋានមិនត្រឹមតែផ្តល់ប្រយោជន៏ដល់ស្រ្តីប៉ុណ្ណោះទេគឺអាចធ្វើអោយមានសមភាពនៅក្នុងសង្គម ដែលក្នុងនោះមានទាំងក្រុមគ្រួសារ កុមារ និងស្រ្តីខ្លួនឯងថែមទៀតផង[3] ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងតំបន់ភាគច្រើននៅក្នុងពិភពលោក សមភាពរបស់ស្រ្តីត្រូវបានបំផ្លាញដោយភាពមិនស្មើគ្នានៅក្នុងប្រវត្តិសាស្រ្ត អំណាចក្នុងការធ្វើការសម្រេចចិត្ត និងឳកាសទទួលបាននូវធនធាន សិទ្ធិ និងការផ្តល់សិទ្ធិសម្រាប់ស្រ្តី[4] ។

## I. ស្ថានភាពបច្ចុប្បន្នរបស់សមាជិកាក្រុមប្រឹក្សានៅក្នុងប្រទេសកម្ពុជា

ស្ថានភាពការងាររបស់ស្រ្តីដែលធ្វើការនៅក្នុងសហគមន៏មានលក្ខណៈខុសគ្នាទូទាំងប្រទេស។ ជាទូទៅ តំណាងជាស្រ្តីត្រូវបានមើលឃើញថាជាឳកាសសម្រាប់លើកកម្ពស់ស្ថានភាពទូទៅរបស់ស្រ្តីជាងតំណាងជាបុរស ។ ប៉ុន្តែ នៅពេលដែលស្រ្តីបង្ហាញពីចំនាប់អារម្មណ៏ និងឆន្ទៈនៅក្នុងការចូលរួម

[1] Kim & Ojendal', *A Gendered Analysis Of Decentralization Reform in Cambodia'*, CDRI, Phnom Penh, 2012.
[2] OXFAM*, Women leading change: Experiences Promoting Women Empowerment, Leadership, and Gender Justice*, Oxfam Novib, 2011.
[3] OXFAM, *Women leading change: Experiences Promoting Women Empowerment, Leadership, and Gender Justice,* 8.
[4] UNFPA, "Promoting Gender Equality". Accessed 11th April 2014 through http://www.unfpa.org/gender/empowerment3.htm

នៅក្នុងនយោបាយថ្នាក់មូលដ្ឋាន[5] កត្តាសង្គម និងសេដ្ឋកិច្ចគឺជាឧបសគ្គដែលរារាំងស្ត្រីពីការចូលរួមអោយបានពេញលេញនៅក្នុងវិស័យនេះដែលធ្វើអោយពួកគេខ្វះខាតនូវសិទ្ធិ និងអំណាចដើម្បីចូលរួមអោយបានពេញលេញនៅក្នុងជីវិតនយោបាយ[6] ។

### I.1 ចំនួនក្រុមប្រឹក្សាជាស្ត្រីធៀបទៅនឹងបុរសនៅក្នុងប្រទេសកម្ពុជា និងធៀបទៅនឹងប្រទេសនៅក្នុងតំបន់

បច្ចុប្បន្ននេះ ស្ត្រីមានចំនួន១២%នៃចំនួនក្រុមប្រឹក្សានៅកម្រិតមូលដ្ឋាន ហើយរហូតមកដល់បច្ចុប្បន្ននេះ ឃុំមួយចំនួននៅមិនទាន់មានតំណាងជាស្ត្រីនៅឡើយទេ ។ នៅថ្នាក់ខេត្ត ស្ត្រីដែលកាន់តំណែងមានត្រឹមតែ៣៧ ក្នុង៣៧៤ តំណែងរបស់ក្រុមប្រឹក្សា និងថ្នាក់ស្រុកស្ត្រីមានចំនួន៣០៦ ក្នុង២,៨៨០ តំណែង ។ សរុបមក ក្នុងចំនោមក្រុមប្រឹក្សាឃុំចំនួន ១៦,០០០ ស្ត្រីមានចំនួនតែ ១៨% តែប៉ុណ្ណោះ (រូបភាព១)[7]។

យើងសង្កេតឃើញថា នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិចនេះ ស្ត្រីដែលធ្វើការនៅថ្នាក់ជាតិបានឈានទៅដល់កម្រិតខ្ពស់នៃភាពជាអ្នកដឹកនាំ ប៉ុន្តែ នៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើដើម្បីជម្រុញតំណាងជាស្ត្រី នៅក្នុងតួនាទីសម្រេចចិត្តនៅថ្នាក់ក្រោមជាតិ ។ ឧទាហរណ៍ គិតត្រឹម២០១០ ចំនួនស្ត្រីជាតំណាងនៅក្នុងតំណែងសំខាន់ៗ នៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ ថ្នាក់ខេត្ត ថ្នាក់តំបន់[8] មានត្រឹមតែ ៣៧% នៅ ប្រទេសឥណ្ឌា ៣០%ប្រទេសអាហ្វហ្គានីស្ថាន ២៩.៤%ប្រទេសណូវែលសេឡង់ ២៧.៨% ប្រ ទេសអូស្ត្រាលី និង ២៣.៨%ប្រទេសវៀតណាម (រូបភាព២) ។ នៅកម្រិតរដ្ឋបាលទាបជាងនេះ តួលេខស្ត្រីក៏មានចំនួនទាបដែរ គឺ ១៥% ប្រទេសអាហ្វហ្គានីស្ថាន ១៩.៨%ប្រទេសហ្វីលីពីន និង១៦%ប្រទេសណូវែលសេឡង់[9] (រូបភាព៣)។

ដើម្បីជម្រុញការចូលរួមរបស់ស្ត្រីនៅថ្នាក់ក្រោមជាតិអោយស្ថិតនៅកម្រិតមួយដែលអាចធ្វើការសម្រេចចិត្តបាន រដ្ឋាភិបាលបានចាត់វិធានការតាមរយៈការតែងតាំងស្ត្រីជាអភិបាលរង១រូបនៅតាមខេត្តនីមួយៗ ។ ដូចដែលបង្ហាញនៅក្នុងរូបភាពទី៤ខាងក្រោម ការបោះឆ្នោតឃុំឆ្នាំ២០១២ ស្ត្រីមានចំនួន

[5] Margherita, M. & Hong, S., *Promoting Political Participation of Indigenous Women in Cambodia*, Heinrich Böll Foundation, Phnom Penh, Cambodia, 2009. Accessed 20th April 2014 through ttp://kh.boell.org/downloads/HBF_Indigenous_Report_-_English_Final.pdf
[6] Margherita, M. & Hong, S., *Promoting Political Participation of Indigenous Women in Cambodia*, 18.
[7] Jean Munro, *Women's representation in leadership in Vietnam*, UNDP, 2012.
[8] UNDP, *Women in Local government in Asia Pacific Status Report,* 2010,
[9] Ibid.

២,០៣៨ (១៧.៧%) ក្នុងចំនោម១១,៤៥៩ ។ តួលេខនេះបង្ហាញពីការកើនឡើងចំនួន ៣% ពីតួលេខឆ្នាំ២០០៧ ដែលមាន១៥.១% (១,៦៦៣ ក្នុង១១,៣៥៣) ជាស្ត្រី ហើយនេះគឺជាការកើនឡើងគួរអោយកត់សម្គាល់នៃ៨.៣% ពីតួលេខនៅឆ្នាំ២០០២ ដែលមានស្ត្រីចំនួនតែ៩.៤% ប៉ុណ្ណោះ (៩៥៤ ក្នុងចំនោម១១,២៦១)[10] ។

**តារាងទី ១: ចំនួនជាភាគរយនៃស្ត្រីនៅថ្នាក់ខេត្ត ឃុំ និងសង្កាត់នៃក្រុមប្រឹក្សារវាងអាណត្តិ ១៩៩៩-២០០៤, ២០០៤-២០១១ និង ២០១១-២០១៦**

| | **១៩៩៤-២០០៤** | **២០០៤-២០១១** | **២០១១-២០១៦** |
|---|---|---|---|
| **ថ្នាក់ខេត្ត** | ២២.៣៣% | ២៣.៨០% | ២៥.៧០% |
| **ថ្នាក់សង្កាត់** | ២០.១២% | ២២.៩៤% | ២៤.៦២% |
| **ថ្នាក់ឃុំ** | ១៦.១០% | ១៩.៥៣% | ២៧.៧១% |

*ប្រភព: Jean Munro, (2012). ភាពជាតំណាងរបស់ស្ត្រីក្នុងថ្នាក់ដឹកនាំនៅប្រទេសវៀតណាម. UNDP*

**តារាងទី២: ការប្រៀបធៀបភាពជាតំណាងក្នុងវិស័យនយោបាយរបស់ស្ត្រីរវាងថ្នាក់ជាតិ និងក្រោមជាតិ ក្នុងខែតុលា ឆ្នាំ២០១០**

| **ប្រទេស** | **តំណាងស្ត្រីថ្នាក់ជាតិ (%)** | **តំណាងស្ត្រីនៅថ្នាក់ក្រោមជាតិសរុប (%)** |
|---|---|---|
| អាហ្វហ្គានីស្ថាន | ២៧.៣ | ៣០ |
| អូស្ត្រាលី | ២៧.៣ | ២៨.១០ |
| ឥណ្ឌា | ១០.៨ | ៣៧ |
| ណូវែលសេឡង់ | ៣៣.៦ | ២៩.៤០ |
| វៀតណាម | ២៥.៨ | ២២.១៤ |

*ប្រភព: របាយការណ៍រដ្ឋាភិបាលមូលដ្ឋាននៅអាស៊ីប៉ាស៊ីហ្វិក ២០១០, UNDP*

[10] National Election Committee (NEC), Updated 2012. Phnom Penh, Cambodia.

**តារាងទី៣: ទិន្នន័យតំណាងជាស្ត្រីដែលបានជាប់ឆ្នោតនៅក្រុមប្រឹក្សានៅជនបទក្នុងខែតុលា ឆ្នាំ២០១០**

| ប្រទេស | តំណាងស្ត្រីជាប់ឆ្នោត | | | ស្ត្រីជាប្រធាន | | |
|---|---|---|---|---|---|---|
| | ចំនួនតំណាងជាប់ឆ្នោតសរុប, រួមទាំងប្រធាន (#) | ចំនួនតំណាងជាប់ឆ្នោតជាស្ត្រី (#) | តំណាងស្ត្រីជាប់ឆ្នោត (%) | ចំនួនប្រធានក្រុមប្រឹក្សា (#) | ចំនួនស្ត្រីជាប្រធានក្រុមប្រឹក្សា(#) | ស្ត្រីជាប្រធានក្រុមប្រក្សា (%) |
| អាហ្គានីស្ថាន: ខេត្ត | ៤២០ | ១២៥ | ៣០ | ៣៤ | ៥ | ១៥ |
| ណូវែលសេឡង់: ភូមិភាគ, ក្រុង និងក្រុមប្រឹក្សា សង្កាត់ | ៩៩៩ | ២៩៤ | ២៩.៤ | ៨៥ | ១៤ | ១៦ |
| ហ្វីលីពីន | NA | NA | NA | ៨១ | ១៦ | ១៩.៨ |

*ប្រភព: របាយការណ៍រដ្ឋាភិបាលមូលដ្ឋាននៅអាស៊ីប៉ាស៊ីហ្វិក ២០១០ ,UNDP*

**តារាងទី៤: ការបោះឆ្នោតឃុំ/សង្កាត់នៅប្រទេសកម្ពុជា**

| អាណត្តិ និងឆ្នាំ | សមាជិកក្រុមប្រឹក្សា | | ប្រធានឃុំសង្កាត់/ | | អនុប្រធានទី១ | | អនុប្រធានទី២ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០០២ | ១១,២១៦ | ១,០៥៦ (៩.៤%) | ១,៦២១ | ៤២ (២.៦%) | ១,៦២១ | ៧២ (៤.៤%) | ១,៦២១ | ៨៦ (៥.៣%) |
| ២០០៧ | ១១,៣៥៣ | ១,៧១៧ (១៥.១%) | ១,៦២១ | ៦៧ (៤.១%) | ១,៦២១ | ១៥១ (៩.៣%) | ១,៦២១ | ១៣១ (៨%) |
| ២០១២ | ១១,៤៥៩ | ២,០៣៨ (១៧.៧%) | ១,៦៣៣ | ៩៦ (៥.៨%) | ១,៦៣៣ | ១៨៩ (១១.៦%) | ១,៦៣៣ | ១៥១ (៩.២%) |

*ប្រភព: គណៈកម្មការជាតិរៀបចំការបោះឆ្នោត NEC, ២០១២*

### I.2. ការដឹកនាំ និង គ្រប់គ្រងរបស់សមាជិកាក្រុមប្រឹក្សា

កម្រនឹងឃើញមានវត្តមានស្ត្រីនៅក្នុងតំណែងជាអ្នកដឹកនាំណាស់ ។ ជាញឹកញាប់ ទោះបីជាស្ត្រីត្រូវបានជ្រើសរើស អោយចូលរួមនៅក្នុងនយោបាយមូលដ្ឋាន ក៏តំណែងរបស់ពួកគេមានកម្រិតទាបនៅឡើយ ជាទូទៅពួកគេមានតួនាទីជាអ្នកគាំទ្រជាជាងតួនាទីជាអ្នកសម្រេចចិត្ត[11] ។

ជារួម កត្តាគន្លឹះផ្សេងៗដែលចាំបាច់ដើម្បីអោយការបញ្ចេញមតិ និងការចូលរួមក្នុងឆាកនយោបាយរបស់ពួកគាត់យ៉ាងពេញលេញនៅថ្នាក់មូលដ្ឋានគឺៈ

- ការទទួលបាននូវធនធានហិរញ្ញវត្ថុ និងសិទ្ធិធ្វើការសម្រេចចិត្តគួរតែមានចែងនៅក្នុងច្បាប់
- ការទទួលបានការគាំទ្រ និងទំនុកចិត្តពីគណបក្សរបស់ពួកគាត់ ទំនាក់ទំនងរយៈពេលយូរជាមួយគណបក្សធ្វើអោយពួកគាត់មានភាពងាយស្រួលក្នុងការបំពេញការងារ ។
- កម្រិតនៃការអប់រំ និងបទពិសោធន៏គ្រប់គ្រាន់ ព្រមទាំងការបង្កើនសមត្ថភាពក្នុងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងហិរញ្ញវត្ថុ ។ល។
- មានការជឿជាក់លើខ្លួនឯង និង
- ប្រជាប្រិយភាព ការគាំទ្រ និងទទួលបានទំនុកចិត្តពីសហគមន៍[12]

អង្គការមួយចំនួននៅក្នុងប្រទេសកម្ពុជាក៏ដូចជាប្រទេសសេរីលង្កាបានផ្តល់យោបល់ពីលក្ខណៈសម្បត្តិមួយចំនួនដែលស្ត្រីជាអ្នកដឹកនាំត្រូវមាន ដូចជា៖

- មានចំនេះដឹង
- សមត្ថភាពជាបុគ្គលដែលមិនលម្អៀង និងជាតំណាងអោយសហគមន៏របស់គាត់ និងផលប្រយោជន៏របស់ប្រជាពលរដ្ឋ មិនមែនសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន
- សមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចចិត្ត
- ស្ទាត់ជំនាញក្នុងការធ្វើទំនាក់ទំនង
- សមត្ថភាពក្នុងការដោះស្រាយបញ្ហា
- មានភាពបត់បែន មានទំនុកចិត្តលើខ្លួនឯង និងមានគំនិតវិជ្ជមាន

[11] Interview Result with NCDD advisor Ms. Henny Anderson and Ms. Mary Sok, 14th December
[12] Kim and Ojendal, 10.

- អព្យាក្រឹត្យ គួរអោយគោរព និងក្លាហាន
- មានសមត្ថភាពបញ្ចុះបញ្ចូល និងលើកទឹកចិត្តអ្នកដ៏ទៃ
- មានការទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន
- អាចលើកយកបញ្ហាមកដោះស្រាយនៅក្នុងវេទិកាសាធារណៈ
- មានសមត្ថភាពចរចារ
- ត្រៀមរួចជាស្រេចក្នុងការប្រថុយនឹងគ្រោះថ្នាក់
- មានសមត្ថភាពធ្វើអោយការចូលរួមទាំងបុរស និងស្ត្រី និង
- ត្រូវបានទទួលស្គាល់ក្នុងតួនាទីជាអ្នកដឹកនាំដោយសហគមន៍របស់ពួកគេ[13]

## II. គោលនយោបាយដែលមានស្រាប់

ដោយយល់ឃើញថាការអភិវឌ្ឍន៍ត្រូវការអោយមានការចូលរួមទាំងបុរស និងស្ត្រី រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការជម្រុញ ស្ថានភាពស្ត្រីនៅក្នុងប្រទេសអោយកាន់តែប្រសើរឡើង ។ តាមរយៈច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ឆ្នាំ ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតនូវកម្រិតថ្នាក់ឃុំ ដោយចាត់ទុកថានេះជាចំនុចគន្លឹះក្នុងការអភិវឌ្ឍន៍ប្រជាធិបតេយ្យ ។ ច្បាប់នេះបង្កើតឡើងដើម្បីផ្តល់ឱកាសអោយសមាជិកក្រុមប្រឹក្សាជាស្ត្រី ធ្វើការងារលើបញ្ហាស្ត្រី និងកុមារ ។ ក្រុមប្រឹក្សាឃុំ/សង្កាត់ត្រូវជ្រើសរើសដោយប្រធាន និងអនុប្រធានភូមិ ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់វិមជ្ឈការ និងសហវិមជ្ឈការ ឆ្នាំ ២០០៥ បង្ហាញពីការអនុវត្តន៍ដំណាក់កាលទី២នៃកំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការ ដែលត្រូវបានអនុវត្ត ឡើងតាមរយៈច្បាប់ស្តីពីការរៀបចំអង្គការឆ្នាំ២០០៨ ដែលផ្តល់អោយនូវការបោះឆ្នោតអសកល ឬមិនផ្ទាល់ ចំពោះ ថ្នាក់ស្រុក/ខណ្ឌ និងខេត្ត/ក្រុង[14] ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះបង្ហាញពីសារៈសំខាន់ពីការយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ ព្រោះបានកំនត់ថា "កំណែទម្រង់នេះនឹងបង្កើតឡើងនូវប្រព័ន្ធ និងនីតិវិធី ដើម្បីធ្វើអោយប្រាកដថាប្រជាពលរដ្ឋទាំងអស់ ជាពិសេសក្រុមស្ត្រីងាយរងគ្រោះ និងជនជាតិភាគតិច មានឱកាសចូលរួមក្នុងការសម្រេចចិត្តនៅថ្នាក់រាជធានី/ខេត្ត និង ក្រុង/ស្រុក/ខណ្ឌ និងឃុំ-សង្កាត់" ។ មានមាត្រាមួយចំនួននៅក្នុងច្បាប់រៀបចំអង្គការដែលទាក់ទងនឹងបញ្ហាយេនឌ័រ និងបង្ហាញយ៉ាងច្បាស់ពីគោលការណ៏នៃសមភាពយេនឌ័រ សិទ្ធិ និងការផ្តល់អំណាចដល់ស្ត្រី

[13] OXFAM, 11.
[14] National Program for Sub-National Democratic Development (NP-SNDD) 2010-2019.

។ ច្បាប់នេះគឺជាមូលដ្ឋានក្នុងការលើកកម្ពស់តួនាទី ការចូលរួម និងតំណាងជាស្ត្រីនៅក្នុងនយោបាយ និងការធ្វើសេចក្ដីសម្រេចចិត្តនៅថ្នាក់រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់[15] ។

បន្ថែមពីលើនេះទៀត រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតកម្មវិធីជាតិរយៈពេល១០ឆ្នាំ សម្រាប់ការអភិវឌ្ឍន៍ប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ(២០១០-២០១៩) ដើម្បីពង្រឹងតួនាទីស្ត្រី និងសមភាពយេនឌ័រនៅថ្នាក់ក្រោមជាតិ ដោយបានកំនត់ថា ការអភិវឌ្ឍន៍ប្រជាធិបតេយ្យថ្នាក់ក្រោមជាតិមានប្រសិទ្ធភាព និងមានចីរភាពលុះត្រាណាតែបញ្ហាយេនឌ័រត្រូវបានដោះស្រាយ។ ទាំងកម្មវិធីជាតិ និងផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង មានបញ្ចូលយុទ្ធសាស្ត្រយេនឌ័រជាមួយនឹងគោលដៅរួម គឺការទទួលបាននូវរដ្ឋបាលថ្នាក់ក្រោមជាតិដែលយកចិត្តទុកដាក់ពីបញ្ហាយេនឌ័រ ក៏ដូចជាការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិដែលលើកកម្ពស់សមភាពយេនឌ័រ និងការផ្ដល់អំណាច ដល់ស្ត្រីនូវរាល់រូបភាពនៅក្នុងដំណើរការអភិវឌ្ឍន៍ប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ[16]។

ទោះបីជារដ្ឋធម្មនុញ្ញកម្ពុជាបានធានានូវសិទ្ធិស្មើគ្នារវាង ស្ត្រី និង បុរសក៏ដោយ ប៉ុន្តែសមត្ថភាពក្នុងការទាមទារសិទ្ធិទាំងនេះនៅតែចោទជាបញ្ហានៅក្នុងសង្គម និងឥរិយាបថទាក់ទងនឹងអំណាច និងយេនឌ័រ[17] ។

## III. **បញ្ហាគន្លឹះ និងការប្រឈមសំខាន់ៗ**

បច្ចុប្បន្ននេះ មានស្ត្រីជាតំណាងប្រមាណ១៨%នៅក្នុងក្រុមប្រឹក្សាឃុំ/សង្កាត់ បើធៀបនឹងឆ្នាំ២០០២ គឺមានតែ៩% ប៉ុណ្ណោះ ។ ស្ត្រីទាំងនេះប្រឈមមុខនឹងឧបសគ្គធំៗមួយចំនួន ហើយ ដែលត្រូវបានបង្ហាញអោយកាន់តែច្បាស់ថា តម្រូវការចាំបាច់នូវយុទ្ធសាស្ត្រមួយចំនួនគួរតែត្រូវបានកំណត់ ដើម្បីគាំទ្រការងារ និងលើកកម្ពស់នូវតួនាទីរបស់ពួកគេនៅថ្នាក់ឃុំ[18] ។

ទោះបីជាមានច្បាប់ និងគោលនយោបាយជាច្រើនដែលជួយជម្រុញសមភាពយេនឌ័រ ក៏ប៉ុន្តែការអនុវត្តនិងការពង្រឹងនៅតែមានភាពយឺតយ៉ាវ។ ជាទូទៅ គោលនយោបាយ និងបទបញ្ញត្តិយេនឌ័រនៅមិន

---

[15] Ibid.
[16] Interview's result with NCDD advisor Ms. Henny Anderson and Mary Sok, 14th December 2012
[17] Siobhan G., Pon, D. & Sok, K. , *Gender and Development in Cambodia: An Overview,* Working Paper 10, CDRI, Phnom Penh, Cambodia, 1999.
[18] OXFAM, 26.

ទាន់បានយល់ពេញលេញនៅឡើយទេ ហើយការលើកកម្ពស់បញ្ហាស្ត្រីនៅថ្នាក់មូលដ្ឋាននៅមិនទាន់មានលក្ខណៈសមស្របទៅនឹងគោលនយោបាយ និងបញ្ញត្តិនានាដែលមានស្រាប់នោះទេ[19]។

ឥទ្ធិពលប្រពៃណី និងផ្នត់គំនិតរបស់ស្ត្រី រួមផ្សំនឹងបទដ្ឋានវប្បធម៌នៅកម្ពុជាផងនោះ ធ្វើអោយជះឥទ្ធិពលដល់ការចូលរួមរបស់ស្ត្រីនៅក្នុងជីវិតនយោបាយ ។ នៅប្រទេសកម្ពុជា អំណាច និងនយោបាយត្រូវបានផ្សាភ្ជាប់យ៉ាងរឹងមាំទៅនឹងចរិកលក្ខណៈរបស់បុរសហើយតាមរយៈការយល់ឃើញនេះ គឺបានបង្ហាញនូវលក្ខណៈបន្ទាប់បន្សំដល់ស្ត្រី។ ស្ត្រីត្រូវបានសង្កេតឃើញថាបានចូលរួមចំណែកសំខាន់នៅក្នុងកិច្ចការផ្ទះ ដែលមិនមែនជាការងារសង្គម ឬនយោបាយ កុំថាឡើយដល់ទៅទាមទារនូវតួនាទីនៅក្នុងលំដាប់ខ្ពស់ ឬ កម្រិតនៃការសម្រេចចិត្តនោះ[20] ។

ជាការចាំបាច់ណាស់ដែលបុរសជាប្តី និងសាច់ញាតិមានការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការលើកកម្ពស់ទំនាក់ទំនងយេនឌ័រ ដើម្បីធ្វើអោយប្រាកដថាអ្នកដឹកនាំជាស្ត្រីទទួលបានការលើកទឹកចិត្តពេញលេញពីដៃគូ ឬក្រុមប្រឹក្សាឃុំ ឬពីគណបក្សនយោបាយរបស់ពួកគេ ។ អ្នកដឹកនាំជាស្ត្រីមិនត្រឹមតែខ្វះខាតនូវការគាំទ្រពីបុរសប៉ុណ្ណោះទេ ពេលខ្លះ ក៏មានការខ្វះខាតនូវការគាំទ្រពីស្ត្រីដូចគ្នាដែរ[21] ។

កង្វះខាតការយល់ដឹង គឺជាកត្តាមួយក្នុងចំណោមកត្តាសំខាន់ៗជាច្រើនដែលពន្យល់ ពីអតុល្យភាពនៃទំនាក់ទំនងយេនឌ័រនៅក្នុងប្រទេសកម្ពុជា ។ កត្តានេះមិនត្រឹមតែជះឥទ្ធិពលដល់ការងារប្រចាំថ្ងៃរបស់ស្ត្រីប៉ុណ្ណោះទេ តែថែមទាំងប៉ះពាល់ដល់ជំនឿចិត្តក្នុងការបំពេញការងាររបស់ពួកគាត់ផងដែរ ជាពិសេសគឺនៅពេលដែលពួកគាត់ត្រូវធ្វើការសម្រេចចិត្តការងារអ្វីមួយ។

ជារឿយៗស្ត្រីនៅតាមខេត្ត មិនត្រូវបានផ្តល់លទ្ធភាពក្នុងការទទួលបាននូវធនធានដែលពួកគេត្រូវការដើម្បីបំពេញតួនាទីអោយបានពេញលេញនៅក្នុងឆាកនយោបាយ ។ ស្ត្រីត្រូវការមានសន្តិសុខផ្នែកសេដ្ឋកិច្ចក្នុងការបំពេញការងាររបស់ពួកគេនៅក្នុងសហគមន៍ ត្រូវការអោយមានមូលនិធិឃុំ/សង្កាត់ ឬមូលនិធិពីរដ្ឋាភិបាលដើម្បីគាំទ្រស្ត្រីនៅក្នុងថ្នាក់មូលដ្ឋាន[22] ។

---

[19] Kim and Ojendal (2012)
[20] Ibid.
[21] Prak and Schuette , Gender and Women Politics in Cambodia, Heinrich Boll Stiffing, Cambodia, 2007.
[22] Kim and Ojendal (2012)

## IV. **បទពិសោធន៍ពីអន្តរជាតិ**

ផ្នែកនេះរួមបញ្ចូលទៅដោយការសិក្សាសំខាន់ៗពី៥អង្គការក្នុងចំណោម៦អង្គការនៃប្រទេស៤ (កម្ពុជា, ឥណ្ឌូនេស៊ី, ហ្វីលីពីន និងស្រីលង្កា) រួមមាន បទពិសោធន៍ក្នុងការតាក់តែង និងអនុវត្តនូវកម្មវិធីក្នុងការលើកកម្ពស់ស្ត្រី បញ្ហា និងការប្រឈមរបស់ពួកគេ និង ប្រសិទ្ធភាពរបស់ពួកគេក្នុងការលើកកម្ពស់ការដឹកនាំ និងផ្តល់អំណាចដល់ស្ត្រី ។

- **របាំងវប្បធម៌ និងប្រពៃណីចំពោះការដឹកនាំ និងការផ្តល់អំណាចដល់ស្ត្រីៈ** ភាគច្រើន ស្ត្រីក្នុងតំបន់អាស៊ានតែងតែទទួលខុសត្រូវការងារផ្ទះ និងថែទាំកូន និងគ្រួសារទាំងមូល ប៉ុន្តែ ពួកគេមិនមានឧបករណ៍ចាំបាច់ដូចជាអំណាចសម្រេចចិត្ត និងការទទួលបាន និង ការគ្រប់គ្រងធនធាន ដើម្បីធ្វើការងារនេះទេ ។ ការខូចប្រយោជន៍ដល់ស្ត្រីគឺមានតាំងពីពេលនៅក្មេងខណៈពេលដែលពួកគេមិនបានទទួលការអប់រំថ្នាក់មូលដ្ឋាន[23] ។

- **លើកតម្កើងស្ត្រីក្នុងការដឹកនាំៈ** ស្ត្រីដែលមានធនធាន ចំណេះដឹង និងអំណាចក្នុងការសម្រេចចិត្តមានឥទ្ធិពលជាវិជ្ជមានក្នុងគ្រួសារ និងសង្គម និងលើសពីនេះទៀត ។ ការអភិវឌ្ឍន៍អាចធ្វើទៅបានប្រសិនបើស្ត្រីមានសម្លេង និងធនធានក្នុងការធ្វើឲ្យជីវិតរបស់ពួកគេ និងគ្រួសារខុសពីអ្នកដទៃ ។ សង្គមត្រូវការតំណាងរបស់ស្ត្រីនៅកម្រិតនយោបាយ មិនត្រឹមតែដើម្បីផលប្រយោជន៍របស់ស្ត្រីប៉ុណ្ណោះទេ ។ វាបង្កើតនូវសង្គមមួយមានសមធម៌ដែលនៅក្នុងនោះផ្តល់ផលប្រយោជន៍ដល់គ្រួសារ កុមារ និងស្ត្រី ។ ស្ត្រីដែលមានលទ្ធភាពរៀន មូលធនសង្គម និងធុរកិច្ចអាចធ្វើការសម្រេចចិត្តបានល្អជាង ហើយនិងអាចចូលរួមលើកតម្កើងផលប្រយោជន៍ស្ត្រីក្នុងឆាកនយោបាយ[24] ។

- **លើកតម្កើងស្ត្រីក្នុងការដឹកនាំមានន័យថាធ្វើការជាមួយបុរស និងស្ត្រីៈ** បុរសត្រូវតែច្បាស់ថាការផ្តល់អំណាចដល់ស្ត្រីមិនមែនជាការបន្ថយអំណាចពីបុរសទេ វាផ្តល់ប្រយោជន៍ដល់ពួកគេ និងគ្រួសាររបស់ពួកគេ ។ អតីតកាល ភាពជូរចត់ និងកំហឹងរបស់ស្ត្រីបាននាំទៅដល់ការប្រឆាំងនឹងបុរសដើម្បីគោលដៅ និងការងារសមភាពយេនឌ័រ ។ ដូច្នេះ បុរសត្រូវតែចូលជិតស្ត្រីតាមវិធីមួយដែលទុកនូវលទ្ធភាពក្នុងការពិភាក្សាជាចំហរ ។ មានការពិភាក្សាជាចំហរជាមួយអ្នក

[23] OXFAM (2011), p. 6-12.
[24] Ibid

ដឹកនាំសហគមន៍ដោយលើកឡើងពីបញ្ហាដែលប្រឈម ទាំងនេះបញ្ជាក់ពីទិដ្ឋភាពវិជ្ជមាននៃតម្លៃវប្បធម៌ គឺជាវិធីដល្អមួយដែលត្រូវតែបន្ត ។ ការពិភាក្សានេះតែងតែផ្តោតលើផ្នែកវិជ្ជមានបញ្ជាក់ ពីតម្លៃវប្បធម៌ និងសាសនាដែលគាំទ្រយុត្តិធម៌យេនឌ័រ[25] ។

## សេចក្តីសន្និដ្ឋាន

ទោះជាស្ត្រីក្នុងប្រទេសកម្ពុជាត្រូវបានធានានូវសិទ្ធិនយោបាយដូចបុរសដោយរដ្ឋធម្មនុញ្ញនៃកម្ពុជាក៏ដោយ ក៏ក្នុងការ អនុវត្តជាក់ស្តែង ស្ត្រីតែងតែត្រូវបានគេរើសអើងផ្នែកនយោបាយ ។ ជាទូទៅគេយល់ឃើញ ថាស្ត្រីមិនមានសមត្ថភាព ដើរតួនាទីជាអ្នកដឹកនាំនយោបាយ បន្ថែមទៅនឹងកំហិតសេដ្ឋកិច្ច និងការរើសអើងផ្សេងទៀតផ្នែកយេនឌ័រ ធ្វើឲ្យស្ត្រី បាត់បង់ប្រយោជន៍ក្នុងការចូលរួម និងការតំណាងនយោបាយ ។

ការរីកចម្រើននូវតួនាទីជាអ្នកដឹកនាំរបស់ស្ត្រី និង ការធ្វើអោយកាន់តែប្រសើរឡើងនូវយុត្តិធម៌យេនឌ័រ ទាមទារនូវការប្តេជ្ញាចិត្តដ៏យូរអង្វែងមួយ ទាក់ទងនឹងការផ្លាស់ប្តូរឥរិយាបថ ជំនឿ និងអត្តចរិត ។ ការផ្លាស់ប្តូរអាច នឹងកើតមានឡើងប្រសិនបើមនុស្សភាគច្រើនចង់ឲ្យកើតឡើង ។ និយាយអោយកាន់តែយល់ ការលើកតម្កើងសិទ្ធិស្ត្រីក្នុងសង្គមគឺដូចជាការផ្គុំរូបភាពអញ្ចឹង គឺយើងត្រូវការគ្រប់ផ្នែកទាំងអស់អោយមានភាពស៊ីសង្វាក់គ្នាដើម្បីបង្កើតជារូបភាពទាំងមូលមួយ ។ ផ្នែកទីមួយ គឺការអប់រំស្ត្រីឲ្យមានចំណេះដឹងសមរម្យមួយពីតួនាទី និងសក្តានុពលរបស់ខ្លួន ។ ផ្នែកទី២ គឺបង្កើតឆន្ទៈនយោបាយដើម្បីផ្តល់អំណាចដល់ស្ត្រី និងពិនិត្យបន្ថែមការអនុវត្តន៍ច្បាប់ផ្នែកយេនដ័រ ។ ផ្នែកសំខាន់មួយទៀតគឺការគាំទ្រពីបុរស ដោយបុរសត្រូវតែផ្លាស់ប្តូរនូវឥរិយាបថរបស់ពួកគេ ទៅលើស្ត្រីដែលជាដៃគូ ទាំងនៅផ្ទះ និងនៅកន្លែងការងារ ដើម្បីធ្វើការសម្រេចបាននូវការលើកតម្កើងតួនាទីនយោបាយរបស់ស្ត្រី ។ ជាចុងក្រោយ ស្ត្រីត្រូវតែមានការជឿជាក់លើខ្លួនឯងដើម្បីពង្រឹងសមត្ថភាព និងមតិរបស់ខ្លួនក្នុងសង្គម ។

---

[25] Ibid

# ឯកសារយោង


1. Interview Result with NCDD advisor Ms. Henny Anderson and Ms. Mary Sok, 14th December 2012
2. Jean Munro, *Women's representation in leadership in Vietnam*, UNDP, 2012.
3. Kim & Ojendal', *A Gendered Analysis Of Decentralization Reform in Cambodia'*, CDRI, Phnom Penh, 2012.
4. Margherita, M. & Hong, S., *Promoting Political Participation of Indigenous Women in Cambodia*, Heinrich Böll Foundation, Phnom Penh, Cambodia, 2009. Accessed 20th April 2014 through ttp://kh.boell.org/downloads/HBF_Indigenous_Report_-_English_Final.pdf
5. National Election Committee (NEC), Updated 2012. Phnom Penh, Cambodia.
6. National Program for Sub-National Democratic Development (NP-SNDD) 2010-2019.
7. OXFAM*, Women leading change: Experiences Promoting Women Empowerment, Leadership, and Gender Justice*, Oxfam Novib, 2011.
8. Prak and Schuette , Gender and Women Politics in Cambodia, Heinrich Boll Stiffing, Cambodia, 2007.
9. Siobhan G., Pon, D. & Sok, K., *Gender and Development in Cambodia: An Overview,* Working Paper 10, CDRI, Phnom Penh, Cambodia, 1999.
10. UNDP, *Women in Local government in Asia Pacific Status Report,* 2010,
11. UNFPA, "Promoting Gender Equality". Accessed 11th April 2014 through http://www.unfpa.org/gender/empowerment3.htm